**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រដ្ឋបាលព្រៃឈើ
នាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើ

ភ្នំពេញ ថ្ងៃទី ខែមិថុនា ឆ្នាំ២០១៤

ក្រុមការងារ វាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ (MRV)
**សូមគោរពជូន**
**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ**

**កម្មវត្ថុ:** របាយការណ៍ស្តីពីលទ្ធផលអង្គប្រជុំបច្ចេកទេសវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់(MRV) លើកទី១១។
**ជូនភ្ជាប់:** -បញ្ជីវត្តមាន.....................................................................................................ចំនួន១ច្បាប់
-របៀបវារៈ...........................................................................................................ចំនួន១ច្បាប់
-ឯកសារបទបង្ហាញ..................................................................................................ចំនួន៣ច្បាប់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ យើងខ្ញុំសូមអនុញ្ញាតជម្រាបជូនឯកឧត្តមប្រតិភូមេត្តាជ្រាបថា កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៤ ក្រុមការងារបច្ចេកទេស វាស់វែង រាយការណ៍ និង ផ្ទៀងផ្ទាត់(REL/MRV) បានរៀបចំកិច្ចប្រជុំលើកទី១១ នៅសណ្ឋាគារ អេហ្វ ស៊ី ស៊ី ដែលទទួលបានលទ្ធផលដូចខាងក្រោម៖

I-**សមាសភាពចូលរួម**

កិច្ចប្រជុំនេះមានសមាជិកចូលរួមចំនួន ១៤ នាក់ (ដូចបញ្ជីវត្តមាននៃឯកសារជូនភ្ជាប់) មកពី៖

-រាជរដ្ឋាភិបាលៈ រដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ក្រសួងបរិស្ថាន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រុមប្រឹក្សាយោបល់ៈ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ(FAO) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA) សមាគមន៍ជនជាតិដើមភាគតិច កម្ពុជា(CIYA) និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP)។

II-**គោលបំណងនៃអង្គប្រជុំ**

គោលបំណងនៃអង្គប្រជុំធ្វើការពិភាក្សាស្តីអំពី៖

-ភាពខុសគ្នារវាង IPCC 1996 GPG 2003 និង IPCC 2006

-លទ្ធភាពនៃការបន្តថវិការរបស់UN-REDD សម្រាប់បន្តអនុវត្តសកម្មភាពលើការងារ REL/MRV

-សាច់រឿងវីដេអូដែលផលិតដោយក្រុមការងារលេខាធិកាដ្ឋានកម្មវិធីរ៉េដបូកកម្ពុជា

-បច្ចុប្បន្នភាពនៃគោលការណ៍ណែនាំបច្ចេកទេសសារពើភ័ណ្ឌព្រៃឈើថ្នាក់ជាតិ (NFI)

III-**ដំណើរការកិច្ចប្រជុំ**

ជាកិច្ចចាប់ផ្តើម លោក Matieu Henry បានធ្វើបទបង្ហាញសង្ខេបចែករំលែកអំពី IPCC 1996 GPG 2003 និង IPCC 2006 និងភាពខុសគ្នារវាងកម្មវិធី(Software)ទាំងបី។

- IPCC 1996 ប្រភពបំភាយឧស្ម័នផ្ទះកញ្ចក់មកពីបម្រែបម្រួលកាប្រើប្រាស់ដី និងព្រៃឈើ (LUCF) និងតម្រូវការព័ត៌មាន ៦ប្រភពគឺ ថាមពល ឧស្សាហកម្ម សារធាតុពល បម្រែបម្រួលកាប្រើប្រាស់ដី និង ព្រៃឈើ កសិកម្ម និងកាកសំណល់។

- GPG 2003 ប្រភពបំភាយឧស្ម័នផ្ទះកញ្ចក់មកពីការប្រើប្រាស់ដី បម្រែបម្រួលការប្រើប្រាស់ដី និង ព្រៃឈើ (LULUCF) និងតម្រូវការព័ត៌មាន ៥ប្រភពគឺ ដីព្រៃឈើ វាលស្មៅ ដីដំណាំកសិកម្ម លំនៅដ្ឋាន ដីសើម និង ដីផ្សេងៗទៀត

- IPCC 2006 ប្រភពបំភាយឧស្ម័នផ្ទះកញ្ចក់មកពី ដីកសិកម្ម ព្រៃឈើ និងការប្រើប្រាស់ដីផ្សេងៗទៀត (AFOLU) និងតម្រូវការព័ត៌មាន ៥ប្រភពគឺ គោលការណ៍ណែនាំទូទៅ និងរបាយការណ៍ ថាមពល ឧស្សាហកម្ម និងការប្រើប្រាស់ផលិតផលកសិកម្ម ព្រៃឈើ និងការប្រើប្រាស់ដីផ្សេងទៀត និងសំរាម។

បន្ទាប់មក លោក Shigeru Ono (JICA) បានធ្វើបទបង្ហាញពីការយកទិន្នន័យមក ធ្វើការគណនាដោយប្រើប្រាស់គោលណ៍ណែនាំរបស់ IPCC ឆ្នាំខុសៗគ្នា។

លោក Mathieu Van Rijn (FAO) បានធ្វើបទបង្ហាញ និងពន្យល់អំពីលក្ខខណ្ឌនៃការសុំពន្យាលទ្ធភាពនៃការគាំទ្រថវិការបស់UN-REDD សម្រាប់បន្តអនុវត្តសកម្មភាពលើការងារ REL/MRV ព្រមទាំងស្នើសុំក្រុមការងារ REL/MRV ចុះហត្ថលេខាលើលិខិតស្នើសុំ UN-REDD បន្តអនុវត្តសកម្មភាពលើការងារ REL/MRV។ ទន្ទឹមនិងនោះ លោក Mathieu Van Rijn (FAO) ក៏បានបង្ហាញអំពីអត្ថបទដែលផលិតដោយក្រុមការងារលេខាធិកាដ្ឋានកម្មវិធីរ៉េដបូកកម្ពុជា សម្រាប់យកទៅផលិតវីដេអូសាច់រឿងក្នុងគោលបំណងផ្សព្វផ្សាយពីការងារ REL/MRV។ បទបង្ហាញចុងក្រោយ រាយការណ៍អំពីបច្ចុប្បន្នភាពនៃគោលការណ៍ណែនាំបច្ចេកទេសសារពើភ័ណ្ឌព្រៃឈើថ្នាក់ជាតិ (NFI)។

## IV-**លទ្ធផលនៃកិច្ចប្រជុំ**

### **១.ភាពខុសគ្នារវាង IPCC 2006 GPG 2003 និង IPCC 1996**

អង្គប្រជុំស្នើសុំអោយមានការរៀបចំវគ្គបណ្តុះបណ្តាលស្តីពី វិធីនៃការធ្វើប្រព្រឹត្តកម្មទិន្នន័យតាមរយៈ ការប្រើប្រាស់កម្មវិធីគោលការណ៍ណែនាំ **GPG 2003 IPCC 1996** ជូនដល់ក្រុមការងារ REL/MRV។

### **២.លទ្ធភាពនៃការបន្តថវិការបស់UN-REDD**

ស្នើសុំឲ្យក្រុមលេខាធិកាដ្ឋានការងាររេដបូកកម្ពុជា បង្ហាញអំពីថវិកាដែលនៅសល់ និងពន្យល់អំពីគម្រោងនៃការចំណាយសម្រាប់អនុវត្តសកម្មភាពការងារREL/MRVជាមុនសិន បន្ទាប់មកក្រុមការងារនិងស្នើសុំយោបល់ថ្នាក់ដឹកនាំធ្វើការសម្រេច។

### **៣.សាច់រឿងវីដេអូផ្សព្វផ្សាយការងារ REL/MRV**

អង្គប្រជុំបានសម្រេចឲ្យមានការបញ្ជាក់អំពីអ្នកសរសេរអត្ថបទ ថាតើគោលដៅនៃការផ្សព្វផ្សាយវីដេអូនេះសម្រាប់ផ្សព្វផ្សាយកម្រិតណា? ប្រសិនបើអ្នកទស្សនាជាប្រជាជននៅមូលដ្ឋាន នោះអត្ថបទត្រូវធ្វើការកែលសម្រួលឲ្យមានអត្ថន័យធម្មតាៗ និងងាយស្រួលយល់។

### **៤.បច្ចុប្បន្នភាពនៃគោលការណ៍ណែនាំបច្ចេកទេសសារពើភ័ណ្ឌព្រៃឈើថ្នាក់ជាតិ (NFI)**

នាពេលបច្ចុប្បន្ន សេចក្តីព្រាងគោលការណ៍ណែនាំបច្ចេកទេសសារពើភ័ណ្ឌព្រៃឈើថ្នាក់ជាតិ(NFI) ស្ថិតនៅក្រោមការពិភាក្សា និងផ្តល់យោបល់នៅឡើយ ហើយក្រុមការងារនឹងផ្ញើរឯកសារពង្រាងនេះទៅអ្នកពាក់ព័ន្ធ ជាពិសេសសាកលវិទ្យាល័យមានជំនាញព្រៃឈើដើម្បីផ្តល់មតិយោបល់។

## VI-**ទិសដៅអនុវត្តបន្ត**

ក្រុមការងារនឹងរៀបចំកិច្ចប្រជុំលើកទី១២ នាថ្ងៃទី២៤ ដល់២៧ ខែកក្កដា ឆ្នាំ២០១៤ នៅខេត្តព្រះសីហនុ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមប្រតិភូមេត្តាជ្រាបជាសេចក្តីរាយការណ៍ ដោយអនុគ្រោះតាមការគួរ។